# ព្រះរាជក្រឹត្យ

នស / រកត /០៦០២ / ១៥៨

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៣៩៩ / ៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :-**

ត្រូវបានបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីបំពេញបេសកកម្មរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ លើវិស័យច្បាប់ និងយុត្តិធម៌ ហើយដែលមានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១.ឯកឧត្តម | ឌិត | មុន្ទី | ប្រធានតុលាការកំពូល | ជាសហប្រធាន |
| ២.ឯកឧត្តម | សុខ | អាន | ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាសហប្រធាន |
| ៣.ឯកឧត្តម | នាវ | ស៊ីថុង | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាអនុប្រធាន |
| ៤.លោកជំទាវ | លី | វួចឡេង | ប្រធានសាលាឧទ្ធរណ៍ | ជាអនុប្រធាន |
| ៥.ឯកឧត្តម | ហេង | វង្សប៊ុនឆាត | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់- | ជាសមាជិក |
| ៦.ឯកឧត្តម | អ៊ុក | រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |

Downloaded from http://www.khmerlaws.com

៧.ឯកឧត្តម សុខ ស៊ីផាន់ណា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាសមាជិក

៨.ឯកឧត្តម សុំ ម៉ានិត រដ្ឋលេខាធិការទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ជាសមាជិក

**មាត្រា ២ :–**

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានទីតាំងស្ថិតនៅទីស្ដីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៣ :–**

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានបេសកកម្ម ផ្ដួចផ្ដើម ជំរុញ ដាក់ឱ្យដំណើរការ និងតាមដានការអនុវត្តនយោបាយ និងកម្មវិធីកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្របតាមទិសដៅរបស់ឧត្ដមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

**មាត្រា ៤ :–**

ភារកិច្ច និងបេសកកម្មរបស់ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥ :–**

សមាជិកនៃក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

**មាត្រា ៦ :–**

ក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវមានអង្គភាពសំរបសំរួលអចិន្ត្រៃយ៍មួយ ជាអ្នកសំរបសំរួលដំណើរការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សា ជាមួយស្ថាប័នរដ្ឋ និងស្ថាប័នអន្តរជាតិនានា ដែលពាក់ព័ន្ធ ។

**មាត្រា ៧ :–**

សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៨ :–**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២*

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

**នរោត្តម សីហនុ**

នស/រកត/០៦០២/១៦៤

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
នៃព្រះរាជាណាចក្រកម្ពុជាសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ ១៤៤ស.ល

ថតចម្លងចែកជូន

រាជធានីភ្នំពេញ.ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

Downloaded from http://www.khmerlaws.com